**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

************

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណី
លេខ ១៩៨៩
ចុះថ្ងៃទី ២១-១២-២០១១

សាលក្រម
លេខ ១១ក្រ២ "ន"
ចុះថ្ងៃទី ២០-០៩-២០១២

-បានបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ២៨-០៨-២០១២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៨៩ ចុះថ្ងៃទី ២១-១២-២០១១ ដោយមានសមាសភាពចូលរួម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] Yoon ភេទប្រុស អាយុ ៥១ ឆ្នាំ ជាតិកូរ៉េ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អាសយដ្ឋានផ្ទះលេខ ២៧៧ ផ្លូវលេខ៣៧១ ក្រុមទី៩ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-និងចុងចម្លើយ ធនាគារ **Camko Bank Limited** ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ អាសយដ្ឋានមជ្ឈមណ្ឌល **P.G.C.T** ជាន់ទី២ ផ្លូវលេខ២៧៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ដែលមានកម្មវត្ថុបណ្តឹង : ប្តឹងសុំទាមទារប្រាក់ចំនួន ៤០០០០(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក ។

**អង្គហេតុ និង ចំនុចវិវាទ**

សាលក្រមដែលទាមទារដោយដើមចោទ

- ប្តឹងសុំទាមទារប្រាក់ចំនួន ៤០០០០(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក ។
-សុំទាមទារជំងឺចិត្តចំនួន ១៥០០០ (មួយម៉ឺនប្រាំពាន់)ដុល្លាសហរដ្ឋអាមេរិក ។
-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។
-សុំឱ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

**ការពន្យល់ត្រួសៗអំពីរឿងហេតុ**

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ **Choi Yoon** ថា ខ្លួនបានបម្រើការងារនៅធនាគារ **Camko Bank Limited** អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ដើមចោទត្រូវបានធនាគារ **Camko Bank Limited** បញ្ឈប់ពីការងារ ដូចមាននៅក្នុងកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១។ នៅក្នុងកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុននេះ ត្រង់របៀបវារៈទី ៥ ក្រុមហ៊ុនបានផ្តល់ប្រាក់បំណាច់បញ្ឈប់ពីការងារឱ្យដើមចោទឈ្មោះ [redacted] **Yoon** ចំនួន ៤០០០០(បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក ប្រសិនបើដើមចោទមិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយរហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១។ លុះដល់ផុតកំណត់ថ្ងៃទី-៣០-ខែ មិថុនា ឆ្នាំ ២០១១ ធនាគារ **Camko Bank Limited** មិនបានផ្តល់ប្រាក់បំណាច់បញ្ឈប់ពីការងារនេះឱ្យដើមចោទ ទើបដើមចោទប្តឹងទាមទារប្រាក់នេះមកតុលាការ ។

Scanned with CamScanner

27/6

## ការអះអាងរបស់ភាគី

-ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីខ្លួនបានធ្វើការនៅក្នុងធនាគារ Camko Bank Limited ជាច្រើនឆ្នាំមកហើយ ហើយត្រូវបានធនាគារបញ្ឈប់ពីការងារនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ កិច្ចប្រជុំម្ចាស់ភាគហ៊ុនបានប្រព្រឹត្តឡើងដោយលើកយករបៀបវារៈ៦យកមកធ្វើការសម្រេច។ នៅក្នុងរបៀបវារៈទី៥ និយាយអំពីការផ្តល់ប្រាក់បំណាច់ពេលបញ្ចប់ពីការងារសម្រាប់អភិបាលដែលត្រូវបណ្តេញចេញ គឺកូនក្តីខ្លួនត្រូវបានទទួលទឹកប្រាក់ចំនួន ៤០០០០(បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ក្នុងលក្ខខណ្ឌកូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារក្រោយពីការបណ្តេញចេញ។ក្រោយពីការបណ្តេញចេញពីតួនាទីជាអភិបាលនៅក្នុងធនាគារ Camko Bank Limited រួចមក កូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារទេ ហើយកូនក្តីខ្លួនបានរង់ចាំទទួលប្រាក់បំណាច់នៅពេលបញ្ចប់ការងារពីធនាគាររហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១។ ប៉ុន្តែធនាគារមិនបានបើកប្រាក់នោះឱ្យមកកូនក្តីខ្លួនឡើយ ដោយហេតុថា លោក [redacted] In Hong ជានាយកប្រតិបត្តិស្តីទីរបស់ធនាគារ Camko Bank Limited បានសរសេរលិខិតស្នើសុំយោបល់អាជីវកម្មចុះថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១១ ទៅលោក Lee Jong Sik ជាអ្នកគ្រប់គ្រង KDIC (សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ) ដើម្បីសុំយោបល់សម្រេចឱ្យខាងធនាគារ Camko Bank Limited គួរ ឬមិនគួរបង់ប្រាក់បំណាច់ពេលបញ្ចប់ការងារឱ្យកូនក្តីខ្លួនជាអតីតអភិបាល។ ដោយកូនក្តីខ្លួនបានរង់ចាំការឆ្លើយតបនឹងសំណើនេះយូរមកហើយ ទើបកូនក្តីខ្លួនសម្រេចដាក់ពាក្យបណ្តឹងទាមទារប្រាក់បំណាច់ចំនួន ៤០០០០(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិកពីធនាគារ Camko Bank Limited មកសាលាដំបូងរាជធានីភ្នំពេញ។ ទាក់ទងទៅនឹងការលើកឡើងរបស់លោកមេធាវីចុងចម្លើយថា ធនាគារ Camko Bank Limited អាចប្រគល់ប្រាក់បំណាច់ចំនួន ៤០០០០ (បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក ឱ្យមកកូនក្តីខ្លួនលុះណាតែខាងធនាគារ Camko Bank Limited ធ្វើសវនកម្មចប់សិននោះពុំត្រឹមត្រូវឡើយ ដោយហេតុថា នៅក្នុងកំណត់ហេតុកិច្ចប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ នៅក្នុងរបៀបវារៈទី ៥ និយាយអំពីការផ្តល់ប្រាក់បំណាច់នៅពេលបញ្ចប់ការងារសម្រាប់អភិបាលដែលត្រូវបណ្តេញចេញកូនក្តីខ្លួនត្រូវបានទទួលទឹកប្រាក់ចំនួន ៤០០០០(បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ក្នុងលក្ខខណ្ឌដែលកូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារក្រោយពីថ្ងៃបណ្តេញចេញ។ ចំពោះការធ្វើសវនកម្មរបស់ក្រុមហ៊ុន KPMG និងក្រុមហ៊ុន PWC បាបបញ្ចប់តាំងពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ហើយក្រុមហ៊ុនទាំងពីរនេះមិនបានបញ្ជាក់ថាកូនក្តីខ្លួនធ្លាក់កំហុសទេ។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា ៖ លោក [redacted] Yoon ដែលបានប្តឹងធនាគារ Camko Bank Limited ដោយបានប្រគល់សិទ្ធិឱ្យលោក [redacted] Jeong Yun ក្នុងការធ្វើបណ្តឹងនេះរួចស្រាប់តែលោក [redacted] Jeong Yun បានធ្វើការប្រគល់សិទ្ធិនេះឱ្យលោកមេធាវី [redacted] ក្នុងការធ្វើបណ្តឹងនេះទៅវិញ។ ដូច្នេះយោងតាមមាត្រា ៥២ និង មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី លោកមេធាវី [redacted] គ្មានសមត្ថភាពជាអ្នកតំណាងដោយអាណត្តិឡើយ។ នៅពេលដែលលោ[redacted] Yoon ត្រូវបានបញ្ឈប់ពីការងារ ធនាគារបានផ្តល់ប្រាក់ឱ្យទៅលោក [redacted] Yoon ជាច្រើនដូចជាលុយថ្លៃសំបុត្រយន្តហោះទៅប្រទេសកូរ៉េវិញ លុយថ្លៃសិក្សាកូននៅប្រទេសកូរ៉េ.....។ល។ ធនាគារបញ្ឈប់លោក [redacted] Yoon ពីការងារដោយសារលោក [redacted] Yoon បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។ យោងតាមមាត្រា ៧៣ នៃច្បាប់ស្តីពីការងារការបញ្ឈប់ពីការងារដោយសារកំហុសធ្ងន់ធ្ងរពុំអាចទទួលបានប្រាក់បំណាច់បញ្ឈប់ពីការងារឡើយ។ ពេលដែលធនាគារបញ្ឈប់លោក [redacted] Yoon ពីការងារនោះលោក [redacted] Yoon ក៏យល់ព្រមទទួលយកការបញ្ឈប់ពីការងារនេះដែរ។ ពេលបញ្ឈប់លោក [redacted] Yoon ពីការងារនោះពិតជាមានកិច្ចប្រជុំមែន តែបដិសេធភស្តុតាងដែលផ្តល់ដោយលោកមេធាវីដើមចោទ។ការទាមទារប្រាក់របស់ដើមចោទគឺផ្អែកលើកំណត់ហេតុប្រជុំចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ហេតុនេះសូមឱ្យលោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទផ្តល់ភស្តុតាងកំណត់ហេតុនោះជាច្បាប់ដើមមកតុលាការ។



Scanned with CamScanner

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍តបថា : នៅពេលប្រជុំនោះកំណត់ហេតុត្រូវបានធ្វើជាភាសាកូរ៉េ ហើយសំណៅដើមគឺភាគីដើមចោទ(ធនាគារ) ជាអ្នកទុក។ បើមិនមានកំណត់ហេតុនេះទេ កូនក្តីខ្លួននៅតែជាអភិបាលដដែល។ ពេលនេះកូនក្តីខ្លួនត្រូវបានបញ្ឈប់ពីការងារហើយ ហេតុនេះកំណត់ហេតុនេះគឺមានសុពលភាព។ កំណត់ហេតុនេះច្បាប់ដើមរកមិនបានទេ ព្រោះខាងធនាគារជាអ្នកទុក។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ : កូនក្តីខ្លួនទាមទារប្រាក់ពីធនាគារដោយផ្អែកលើកំណត់ហេតុចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ដោយកំណត់ហេតុនេះសម្រេចផ្តល់ប្រាក់ឱ្យកូនក្តីខ្លួនចំនួន ៤០០០០(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក ប្រសិនណាបើកូនក្តីខ្លួនមិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១១។ នៅក្នុងអំឡុងពេលនេះកូនក្តីខ្លួននៅស្ងៀមមិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយឡើយ។ ហេតុនេះក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទសុំទាមប្រាក់ចំនួន ៤០០០០(បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក ផ្អែកលើកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១។ សុំទាមទារជំងឺចិត្តចំនួន ១៥០០០(មួយម៉ឺនប្រាំពាន់) ដុល្លាសហរដ្ឋអាមេរិក។ សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន និង សុំឱ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា : លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទទាមទារប្រាក់ពីធនាគារដោយផ្អែកលើកំណត់ហេតុប្រជុំចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ប៉ុន្តែពុំបានផ្តល់កំណត់ហេតុនេះជាច្បាប់ដើមមកតុលាការឡើយ ហេតុនេះសូមច្រានចោលការទាមទាររបស់ដើមចោទ។

**ចំនុចវិវាទ :**

-ដើមចោទទាមទារប្រាក់ដើមចំនួន ៤០០០០ (បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក ដោយផ្អែកលើកំណត់ហេតុប្រជុំចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ទាមទារជំងឺចិត្តចំនួន ១៥០០០ (មួយម៉ឺនប្រាំពាន់)ដុល្លាសហរដ្ឋអាមេរិក ទាមទារអនុវត្តសាលក្រមជាបណ្តោះអាសន្ន និង ទាមទារឱ្យចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី តែចុងចម្លើយសុំច្រានចោលការទាមទារនេះ។

បានឃើញកំណត់ហេតុប្រជុំចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១

បានឃើញ ភស្តុតាងជាឯកសារដែលផ្តល់ដោយគូភាគី

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ

ក្រោយពីបានពិនិត្យភស្តុតាងនៅដំណាក់កាលនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

**សំអាងហេតុ**

-ពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ របស់ដើមចោទឈ្មោះ [redacted] Yoon មានលក្ខណៈត្រឹមត្រូវតាមមាត្រា ៨ និង មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-តាមសេចក្តីថ្លែងការណ៍របស់លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថា កូនក្តីខ្លួនបានធ្វើការនៅក្នុងធនាគារ **Camko Bank Limited** ជាច្រើនឆ្នាំមកហើយ ហើយត្រូវបានធនាគារបញ្ឈប់ពីការងារនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១។ នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ កិច្ចប្រជុំម្ចាស់ភាគហ៊ុនបានប្រព្រឹត្តឡើងដោយលើកយករបៀបវារៈ៦យកមកធ្វើការសម្រេច។ នៅក្នុងរបៀបវារៈទី ៥ និយាយអំពីការផ្តល់ប្រាក់បំណាច់ពេលបញ្ចប់ការងារសម្រាប់អភិបាលដែលត្រូវបណ្តេញចេញ គឺកូនក្តីខ្លួនត្រូវបានទទួលទឹកប្រាក់ចំនួន ៤០០០០(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ក្នុងលក្ខខណ្ឌកូនក្តីខ្លួនមិនបានប្រព្រឹត្តធ្វើអសីលធម៌ណាមួយចំពោះធនាគារក្រោយពីការបណ្តេញចេញ ។ ក្រោយពីការបណ្តេញចេញពីតួនាទីជាអភិបាលនៅក្នុងធនាគារ **Camko Bank**-

Limited រួចមក កូនក្តីខ្លួនមិនបានប្រព្រឹត្តទង្វើអសីលធម៌ណាមួយចំពោះធនាគារទេ ហើយកូនក្តីខ្លួនបានរង់ចាំទទួលប្រាក់បំណាច់នៅពេលបញ្ចប់ការងារពីធនាគាររហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ។ ប៉ុន្តែធនាគារមិនបានបើកប្រាក់នោះឱ្យមកកូនក្តីខ្លួនឡើយ ដោយហេតុថាលោក [redacted] In Hong ជានាយកប្រតិបត្តិស្តីទីរបស់ធនាគារ Camko Bank Limited បានសរសេរលិខិតស្នើសុំយោបល់អាជីវកម្មចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ទៅលោក [redacted] Jong Sik ជាអ្នកគ្រប់គ្រង KDIC (សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ) ដើម្បីសុំយោបល់សម្រេចឱ្យខាងធនាគារ Camko Bank Limited គួ ឬ មិនគួបង់ប្រាក់បំណាច់ពេលបញ្ចប់ការងារឱ្យកូនក្តីខ្លួនជាអតីតអភិបាល ។ ដោយកូនក្តីខ្លួនបានរង់ចាំការឆ្លើយតបនឹងសំណើនេះយូរមកហើយ ទើបកូនក្តីខ្លួនសម្រេចដាក់ពាក្យបណ្តឹងទាមទារប្រាក់បំណាច់ចំនួន ៤0000(បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិកពីធនាគារ Camko Bank Limited ។

-តាមសេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថា លោក [redacted]Yoon ដែលបានប្តឹងធនាគារ Camko Bank Limited ដោយបានប្រគល់សិទ្ធិឱ្យលោក[redacted] Jeong Yun ក្នុងការធ្វើបណ្តឹងនេះរួចស្រាប់តែលោក[redacted] Jeong Yun បានធ្វើការប្រគល់សិទ្ធិនេះឱ្យលោកមេធាវី[redacted] ក្នុងការធ្វើបណ្តឹងនេះទៅវិញ ។ ដូច្នេះយោងតាមមាត្រា ៥២ និង មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី លោកមេធា[redacted] គ្មានសមត្ថភាពជាអ្នកតំណាងដោយអាណត្តិឡើយ ។ នៅពេលដែលលោក [redacted] Yoon ត្រូវបានបញ្ឈប់ពីការងារ ធនាគារបានផ្តល់ប្រាក់ឱ្យទៅលោក [redacted] Yoon ជាច្រើនដូចជា លុយថ្លៃសំបុត្រយន្តហោះទៅប្រទេសកូរ៉េវិញ លុយថ្លៃការសិក្សារបស់កូននៅប្រទេសកូរ៉េ..... ។ ល ។ ធនាគារបញ្ឈប់លោក [redacted] Yoon ពីការងារដោយសារលោក [redacted]Yoon បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ។ យោងតាមមាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ការបញ្ឈប់ពីការងារដោយសារកំហុសធ្ងន់ធ្ងរពុំអាចទទួលបានប្រាក់បំណាច់បញ្ចប់ពីការងារឡើយ ។ ពេលដែលធនាគារបញ្ឈប់លោក[redacted] Yoon ពីការងារនោះលោក [redacted]Yoon ក៏យល់ព្រមទទួលយកការបញ្ឈប់ពីការងារនេះដែរ ។ ពេលបញ្ឈប់លោក [redacted] Yoon ពីការងារនោះពិតជាមានកិច្ចប្រជុំមែន តែបដិសេធភស្តុតាងដែលផ្តល់ដោយលោកមេធាវីដើមចោទ ។ ការទាមទារប្រាក់របស់ដើមចោទគឺផ្អែកលើកំណត់ហេតុប្រជុំចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ ហេតុនេះសូមឱ្យលោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទផ្តល់ភស្តុតាងកំណត់ហេតុនោះជាច្បាប់ដើមមកតុលាការ ។

-តាមកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១១ បញ្ជាក់ត្រង់របៀបវារៈទី៥ ថា នឹងប្រគល់ប្រាក់បណ្តេញចេញពីការងារជូនលោក Choi Yoon ចំនួន ៤0000 (បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក នៅថ្ងៃទី ៣០ ខែ មិថុនា ឆាំ ២០១១ លុះណាតែលោក [redacted]Yoon មិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយចំពោះធនាគារក្រោយពីការបណ្តេញចេញ ។

-តាមការអះអាងរបស់លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ តាមការអះអាងរបស់លោកមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ តាមកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១១ ឃើញថាពិតជាមានការប្រជុំម្ចាស់ភាគហ៊ុននៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ពិតប្រាកដមែន ហើយនៅត្រង់របៀបវារៈទី ៥ នៃកំណត់ហេតុនេះ បានសម្រេចថានឹងត្រូវប្រគល់ប្រាក់បណ្តេញចេញពីការងារជូនលោក [redacted] Yoon ចំនួន ៤0000 (បួនម៉ឺន) ដុល្លាសហរដ្ឋអាមេរិក នៅថ្ងៃទី ៣០ ខែ មិថុនា ឆាំ ២០១១ លុះណាតែលោក [redacted] Yoon មិនបានប្រព្រឹត្តអំពើអសីលធម៌ណាមួយចំពោះធនាគារ ក្រោយពីការបណ្តេញចេញ ប៉ុន្តែលោកមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយមិនបានផ្តល់នូវមធ្យោបាយការពារខ្លួនដែលបញ្ជាក់ពីកំហុសរបស់លោក[redacted]Yoon ចាប់ពីថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ឡើយ ហេតុនេះតុលាការទទួលស្គាល់ថា លោក [redacted]Yoon មិនបានប្រព្រឹត្តនូវអំពើអសីលធម៌ណាមួយក្រោយពីថ្ងៃបណ្តេញចេញនោះទេ ។ ដូច្នេះការទាមទារប្រាក់របស់លោក[redacted] Yoon ដោយផ្អែកលើកំណត់ហេតុប្រជុំម្ចាស់ភាគហ៊ុនចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការអាចពិចារណាបាន ។ តាមមាត្រា ២៩ នៃក្រឹតច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-លោកមេធាវីដើមចោទទាមទារជម្ងឺចិត្តចំនួន១៥000 (មួយម៉ឺនប្រាំពាន់) ដុល្លាសហរដ្ឋអាមេរិក តុលាការនឹងពិចារណាពីបញ្ហានេះតាមសភាពជាក់ស្តែង ។

Scanned with CamScanner

-លោកមេធាវីដើមចោទសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន កំប៉ុន្តែលោកមេធាវីដើមចោទមិនបានដាក់ប្រាតិភោគមកតុលាការនោះទេ ហេតុនេះតុលាការមិនគប្បីឱ្យអនុវត្តសាលក្រមជាបណ្តោះអាសន្នឡើយ តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយយោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-រឿងក្តីនេះតុលាការអស់លទ្ធភាពក្នុងការផ្សះផ្សារហើយ

-យោងតាមមាត្រា ២៩ នៃក្រឹតច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យានឹងការទទួលខុសត្រូវក្រៅកិច្ចសន្យា និង មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ
## សម្រេចសេចក្តីបញ្ចប់

១-បង្គាប់ឱ្យចុងចម្លើយធនាគារ **Camko Bank Limited** ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិសងប្រាក់ឱ្យទៅដើមចោទឈ្មោះ [redacted] **Yoon** ភេទប្រុស អាយុ ៥១ ឆ្នាំ ជាតិកូរ៉េ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិចំនួន ៤០០០០(បួនម៉ឺន)ដុល្លាសហរដ្ឋអាមេរិក។

២-បង្គាប់ឱ្យចុងចម្លើយធនាគារ **Camko Bank Limited** សងសំណងជំងឺចិត្តឱ្យ ទៅឈ្មោះ [redacted] **Yoon** ចំនួន ៨.០០០.០០០(ប្រាំបីលានរៀល) ទារលើសពីនេះច្រានចោល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ ចំពោះមុខដើមចោទ និង ចុងចម្លើយ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ហត្ថលេខា និងត្រា :** [redacted]

---

**បានឃើញ**

ភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]

"បានចំលងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២

**ក្រឡាបញ្ជី**

[redacted]

បានទទួលនូវមេធាវី ស៊ុំ ប៊ុនធឿន

23/11/2012

[redacted]

បានទទួល

03/12/2012

[redacted]

៣៦